**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង
# ស្តីពី
# ការព្យួរការងារនៃរោងចក្រ អេចខេ ប៊ុលតិច មេនូហ្វេកធើរី ៦.ក

ឆ្នាំពីរពាន់ម្ភៃបី ខែមីនា ថ្ងៃទីម្ភៃបី វេលាម៉ោង ប្រាំបួន និងដប់នាទីព្រឹកនៅក្នុងបន្ទប់ប្រជុំលេខ១ នៃរោងចក្រ អេចខេ ប៊ុលតិច មេនូហ្វេកធើរី ៦.ក បានបើកកិច្ចប្រជុំមួយស្តីពី ព្យួរកិច្ចសន្យាការងារ នៅក្នុងរោងចក្រ អេចខេប៊ុលតិច មេនូហ្វេកធើរី ៦.ក ដែលមានអាសយដ្ឋានស្ថិតនៅក្នុងសួនឧស្សាហកម្មវឌ្ឍនៈ២ អគារលេខ៩ ភូមិព្រៃសំព័រ សង្កាត់ក្រាំងពង្រ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

## I- សមាសភាពចូលរួមប្រជុំ

១- នាយកក្រុមហ៊ុន

២- អ្នកបកប្រែភាសាចិន

៣- រដ្ឋបាល

៤- ប្រតិភូបុគ្គលិក

៥- ប្រធានផ្នែក ប្រធានក្រុម

(មានភ្ជាប់ជូននូវបញ្ជីវត្តមាន)

## II- របៀបវារៈ

ករណីកម្មករ និយោជិត មានកិច្ចប្រជុំពិភាក្សា រវាងនាយកក្រុមហ៊ុន និងប្រតិភូបុគ្គលិកប្រចាំក្រុមហ៊ុន ស្តីពីការព្យួរកិច្ចសន្យាការងារ ដោយមូលហេតុនៅពេលថ្មីៗនេះ ដោយសារតែកង្វះការបញ្ជាទិញ ដែលជាបញ្ហាដ៏ធំមួយធ្វើឲ្យមានបញ្ហាស្ទះលំហូរផលិតកម្មយ៉ាងធ្ងន់ធ្ងរ ។

## III- យន្តការ និងដំណើរការដោះស្រាយ

ជាកិច្ចចាប់ផ្តើម លោកស្រីប្រធានអង្គប្រជុំបានមានមតិស្វាគមន៍និងសំណេះសំណាលជាមួយនឹងប្រតិភូបុគ្គលិកប្រចាំក្រុមហ៊ុន ប្រធានផ្នែក ប្រធានក្រុម ជាតំណាងឱ្យកម្មករ និយោជិត ដែលបានចូលរួមប្រជុំស្តីពីការព្យួរកិច្ចសន្យាការងារ ។ ការផ្តល់ជូនប្រាក់ឧបត្ថម្ភនឹងត្រូវផ្តល់ជូននៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០២៣ ។

## IV- លទ្ធផល

ឆ្លងតាមការប្រជុំពិភាក្សារួចមក ភាគីទាំងពីរបានឯកភាពគ្នាដូចខាងក្រោមៈ

១-ភាគីទាំងពីរយល់ព្រមព្យួរកិច្ចសន្យាការងាររយៈពេលពីរខែ ចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី៣១ខែឧសភាឆ្នាំ២០២៣ ចំនួន១១៣នាក់ ស្រី៧៦នាក់ នៃកម្មករសរុប ២៩៤នាក់ ស្រី១៧៩ ។

២-ក្រុមហ៊ុននឹងធ្វើការជូនដំណឹងទៅរាល់ប្រធានក្រុមទាំងអស់ ករណីមានការបញ្ជាទិញឡើងវិញបានក្នុងរយៈពេលព្យួរកិច្ចសន្យាការងារខាងលើ ។ ហើយប្រធានក្រុម គ្រប់ផ្នែកក្រុម ត្រូវធ្វើការទំនាក់ទំនងទៅ

សមាជិក ក្នុងក្រុមរបស់ខ្លួនដើម្បីជូនដំណឹងចូលធ្វើការ។

៣-ភាគីទាំងពីរយល់ព្រមទទួល យកការផ្តល់ប្រាក់ឧបត្ថម្ភចំនួន ៣០ ដុល្លារ ក្នុងមួយខែ (សាមសិប ដុល្លារ ) ក្នុងរយៈពេលព្យួរកិច្ចសន្យាការងារខាងលើនេះ ។

៤-ក្នុងករណីបងប្អូនកម្មករ មិនបានចូលធ្វើការវិញតាមការកំណត់នេះទេ ក្រុមហ៊ុននិងអនុវត្តតាមច្បាប់ស្តីពីការងារ និង បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង នាថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសរីករាយ និង ស្និទ្ធស្នាលក្រៃលែង ។

| តំណាងក្រុមហ៊ុន | ប្រតិភូបុគ្គលិក | អ្នកធ្វើកំណត់ហេតុ |
|---|---|---|
| HK BURLTEX MANUFACTORY CO., LTD. KINGDOM OF CAMBODIA<br>MO YANJIE | | |